# សង្គហវត្ថុកថា

## បញ្ហាចោទឆ្លើយ ដើម្បីបំភ្លឺធមិសាមគ្គី

រៀបរៀងដោយ

ព្រះគ្រូបុរត្ថិមវាសី អ៊ូ-ចេវ ព្រហ្មត្ថេរប្បបញ្ញោ

អធិបតីសមាជិកនៃសាលាពុទ្ធិកបឋមសិក្សាវត្តលង្កា

នៅថ្ងៃ៧ ៗ ១១ ៨ ឆ្នាំកុរឯកស័ក ព.ស.២៥០២

ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា គ.ស.១៩៥៩



# ឧប្បត្តិកថា

បុព្វហេតុដែលនាំឲ្យខ្ញុំរៀបរៀង សង្គហធម៌ ដែលជាចំណង សាមគ្គីនេះឡើង ដោយខ្ញុំមានបំណងចង់លើកស្ទួយមនុស្សគ្រប់សញ្ជាតិ ក្នុងពិភពលោកទាំងមូលឲ្យចេះស្រឡាញ់រាប់អានគ្នា មានការទាក់ទងរួម រស់ជាមួយគ្នា ដើម្បីជៀសវាងការប្រមាថមើលងាយគ្នានិងគ្នា ទាំងក្នុង បច្ចុប្បន្ននិងអនាគតដ៏ខ្លីនោះ។

ខ្ញុំមានសង្ឃឹមថា កាលបើធម្មកថានេះផ្សាយចេញទៅដល់ត្រឹមណា គោលបំណងរបស់ខ្ញុំនឹងបានសម្រេចដល់ត្រឹមណោះពុំលែងឡើយ។

ស្រាប់តែនៅពេលថ្មីៗនេះ ស្មៀនល្វៃ អ្នកចម្រៀងល្បីល្បាញក្នុង វង់ភ្លេងពន្លករស្មីកម្ពុជា បានអារាធនាឲ្យខ្ញុំរៀបរៀងអត្ថបទស្របជាមួយ ដោយគេយល់ថា ធម៌អាថ៌មានច្រើនគរគោកក៏ពិតមែន ប៉ុន្តែមានអត្ថន័យ ជ្រាលជ្រៅណាស់ សាមញ្ញជនអ្នកទន់ខ្សោយសិក្សាតិច មិនអាចស្តាប់ យកសេចក្តីបានដោយងាយឡើយ គេមានសង្ឃឹមទៀតថាៈ ចម្រៀងរបស់ គេសព្វថ្ងៃមានឥទ្ធិពល អាចធ្វើជនសាមញ្ញឲ្យយល់ច្បាស់នូវអានុភាពដ៏ ស័ក្តិសិទ្ធិនៃព្រះពុទ្ធសាសនានឹងរស្មីកម្ពុជា ឯករាជ្យ អព្យាក្រិតភាព ដែល ជាថ្វីព្រះហស្តរបស់ សម្តេចព្រះនរោត្តមសីហនុ ឧបយុវរាជ ព្រះ

បិតាឯកករាជ្យជាតិ ព្រះអង្គជាមេដឹកនាំព្រមទាំងសហការី បានតស៊ូដរាបដល់បានសម្រេចក្រោមព្រះរាជសម្ភារៈនៃ ព្រះធានធរោត្តម សុរាម្រឹត និងសម្ដេចព្រះមហាក្សត្រិយានី សាមញ្ញជនអាចនឹងស្គាល់បានដោយងាយដង។ នោះខ្ញុំក៏ព្យាយាមរៀបរៀងអត្ថបទនេះ ឲ្យបានស្របតាមឆន្ទៈដូចខាងលើដរាបដល់បានចប់ជាសេចក្ដីសង្ខេប ដើម្បីទុកជាកតញ្ញូតាកតវេទិតាដ៏ខ្ពង់ខ្ពស់វិសេស បូជាចំពោះព្រះអង្គតរៀងទៅ ឯអត្ថបទធមិនេះ ដូចមានសេចក្ដីតទៅទំព័រខាងមុខ។

សូមគោរពចំពោះករីទាំងឡាយដែលបានជួយពិនិត្យសៀវភៅនេះ គឺ:

១–ព្រះតេជគុណព្រះញាណកោសល ញាណ-ឈឹង ក្រុមជំនុំព្រះត្រៃបិដក ដែលខំប្រឹងជួយផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវល្អ ហើយសុទ្ធតែមានគោលព្រះពុទ្ធសាសនាជាគ្រឿងវិសោធពីក្នុងគម្ពីរពិតៗ តាំងពីដើមដល់ចប់ ដោយឥតគិតកម្លាំងនឿយហត់អ្វីសោះ សូមនឹកគុណជានិច្ច។

២–ព្រះមហា **ឱម-សុជាត់** ចៅអធិការវត្តលួងមង្គលបូរី បាត់ដំបងជាអ្នកឧបត្ថម្ភ តម្លៃបោះពុម្ពនិងការផ្សេងៗ។

៣–ព្រះមហា ពេជ្រ-ប៊ូ បានជួយចម្លងនិងជួយពិនិត្យពាក្យពេចន៍ខ្លះដរាបដល់ចប់។

៤–ព្រះមហា ស៊ូ-ង៉ាន ជួយពិនិត្យពាក្យពេចន៍ដូចគ្នា។

ដោយព្រះគ្រូបុវត្ថិមវាសី ព្រហ្មត្ថេរប្បញ្ញោ ជាអ្នករៀបរៀងផ្ដើមឡើង។

វត្តលង្កា នៅថ្ងៃ៥ ៉ ៨ ឆ្នាំកុរឯកស័ក ព.ស.២៥០២ ត្រូវនឹងថ្ងៃទី ២៩ កក្កដា ១៩៥៩។

# នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះប្រជុំបីនៃព្រះរតនៈ គឺព្រះពុទ្ធ ព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព។

## សង្គហវត្ថុកថា[១]

ពាក្យពេចន៍ដែលថ្លែងអំពីសេចក្ដីសង្គ្រោះ ជាពាក្យសម្រាប់ចងមិត្តភាពឲ្យបានមូលមតិគ្នា ជាក្រុម ជាពួក ជាគណៈ ជាសង្គម សមគួរតាមធម៌ ហៅថាសង្គហវត្ថុ។ នោះមាន៤យ៉ាងគឺៈ **ទាន:** ការចាយវាយធនធានតាមកាល១, **បេយ្យវជ្ជៈ** ការថ្លែងកថាជាទីពីរោះពេញចិត្ត១, **អត្ថចរិយា** ការប្រព្រឹត្តិធ្វើអំពើជាប្រយោជន៍១, **សមានត្តតា** ភាពជាអ្នកពាបសាសមនឹងសមត្ថភាព១។ ធម៌ទាំង៤ប្រការនេះ រមែងវេញសព្វសត្តនិករឲ្យចូលផ្លូវមួយ ដូចជាខ្សែស្រូតឬអម្បោះ ដែលគេវេញបញ្ចូលផ្លូវច្រើនសរសៃឲ្យទៅជាពួរហើយ អាចទាញដំរីសារឲ្យធ្លាក់ក្នុងជ្រោះជ្រៅបាន។

ម្យ៉ាងទៀតដូចជាភ្លៅរបស់ចក្រ ដែលអាចញ៉ាំងកងចក្រឲ្យវិលទៅមិនមានទីបំផុតយ៉ាងណាមិញ បើធម៌សង្គ្រោះទាំង៤នេះ មានស្មើគ្នាហើយ

*១–មង្គលត្ថទីបនី ចតុត្ថគាថា មាតាបិតុបដ្ឋានកថា ទុតិយភាគ ទំព័រ២៤៤ ភាសាថៃ ទំព័រ៣១១។*

ក៏មានកម្លាំងអាចការពារសឹកសត្រូវបានគ្រប់ជំពូក ទាំងអាចឲ្យបានសុខសាន្តត្រាណគ្រប់គ្នាដូច្នោះដែរ។

សមដូចព្រះពុទ្ធតម្រាស់ថា: **សាមគ្គី សាមគ្គានំ តបោ សុខោ** សេចក្តីព្រមព្រៀងរបស់អ្នកមានចិត្តស្មោះត្រង់នឹងគ្នាជា តបគុណ នាំមកនូវសេចក្តីសុខសាន្តត្រាណយ៉ាងនេះឯង។

បណ្ឌិតទាំងឡាយ លោកពិចារណាឃើញច្បាស់នូវសង្គហវត្ថុនេះថា ជាគុណមានប្រយោជន៍ធំទូលាយដល់ម្ល៉ោះហើយ ទើបលោកព្យាយាមបំពេញសង្គហធម៌ទាំង៤នេះតាមកម្លាំង ហើយលោកបានទទួលសេចក្តីសុខនិងពាក្យសរសើរពេញសកលលោក ដូចនិទានរឿងព្រះមហោសថនិងធនញ្ជយបណ្ឌិតបរមពោធិសត្វជាដើម[១]។

បន្ទាប់ពីនេះ សូមអធិប្បាយអំពីសង្គហៈមួយៗឲ្យងាយស្តាប់ ព្រោះធម៌នេះពួកអ្នកសិក្សាគេចេះដឹងស្ទើរតែគ្រប់គ្នាហើយដែរ ប៉ុន្តែនូវខ្វះការអនុវត្តន៍ ការបំពេញមិនទាន់គ្រប់គ្រាន់តែប៉ុណ្ណោះ ជួនកាលបានមួយនៅខ្វះ២-៣ក៏មាន ដូច្នេះហើយបានជាការស្រឡាញ់រាប់អានគ្នា ឆាប់សាបរលាបបាត់បង់វិញ យូរៗទៅប្រែជាស្អប់គ្នាផងក៏សឹងមាន ហេតុនេះ ខ្ញុំសូមអធិប្បាយពីសង្គហវត្ថុនោះពិស្តារតទៅ។

១–សូមជ្រាបតាមមហោសថជាតកនិងគម្ពីរលោកន័យផងចុះ។

១–ទាន: ទោះបីមាតាបិតាក្តី កូនប្រុសស្រីក្តី គ្រូអាចារ្យក្តី ឥស្សរជនណាមួយក្តី មានសន្តានប្រកបដោយមេត្តាអាណិតបុត្រធីតា សិស្សានុសិស្សនិងករុណាដល់បណ្ដារាស្ត្រតូចតាច ក៏លោកទាំងនោះលះធនធានទំនុកបម្រុងបុត្តធីតាគ្រាន់បានចិញ្ចឹមជីវិត ស្លៀកពាក់និងរៀនសូត្យចំណេះវិជ្ជាផ្សេងៗ រហូតដល់បានគូស្រករ ទីលំនៅបានបុណ្យស័ក្តិតាមសមគួរដល់វាសនារបស់ខ្លួនៗ លុះដល់សម័យមកខាងក្រោយបុត្តធីតា សិស្សានុសិស្សនិងប្រជារាស្ត្រអ្នកតូចតាចទាំងនោះប្រែជាមិននឹកនា មិនដែលមកគោរពតបគុណម្តងសោះ ចេះតែបាត់សូន្យទៅ មិនសូវឃើញមានធ្វើសង្គហធមិតបវិញដល់ម្តងតើ ហេតុអ្វី? ត្រង់នេះហើយដែលថា ធ្វើបាន១ ខ្វះ២-៣ គឺបានត្រង់ឲ្យទានទ្រព្យសម្បត្តិចាយវាយម្យ៉ាង នៅខ្វះសម្តីពីរោះជាសង្គហៈទី២ ខ្វះធ្វើប្រយោជន៍ជាសង្គហៈទី៣ ខ្វះសេចក្តីរាបសាស្មើជាសង្គហៈទី៤។ តាមការពិតថាបើបានឲ្យទានជាសង្គហៈទី១ហើយ គោងនិយាយពាក្យពីរោះផ្អែមល្ហែមទៅរកជង កុំពោលពាក្យរំលើកបើកកកាយតាមក្រោយឬពោលទ្រគោះបោះបោកអាក្រក់ឃោរឃៅ នាំអ្នកតូចតាចមានសេចក្តីអៀនខ្មាសឡើយ ត្រូវបំពេញធមិ២ទៀតគឺ បេយ្យវជ្ជៈ ពាក្យផ្អែមល្ហែម។ គោងបំភ្លឺប្រយោជន៍ដូច្នេះថា សំពត់អាវកើតមកអំពីរោងតម្បាញ ម្ហូបចំណីកើតមកពីភោជនីយស្ថាន ដែលនាយវិសេសអាស្រ័យ

បឹង, ស្ទឹង, ព្រែកក្នុងទឹកឬលើគោក, គេហស្ថានកើតមកពីសម្ភារៈផ្សេងៗ ដែលនាយចាំងឈើស្វែងរកមកអំពីព្រៃឬឡឥដ្ឋស៊ីម៉ង់ត៍។ ព្រោះកូនចៅទាំងនោះ កាលណាបរិភោគប្រើប្រាស់អំណោយអស់ទៅ វានឹងស្វែងរកខ្លួនឯងទៅទៀតបានដោយងាយ, ត្រូវបំពេញធម៌ទី៣ គឺ **អត្ថចរិយា** ថែមទៀត។ ទោះបីបានឲ្យទាន និយាយពាក្យពីរោះផ្អែមល្ហែម ប្រព្រឹត្តជាប្រយោជន៍ទាំងបីស្ថានដូច្នេះហើយ ប៉ុន្តែនៅខ្វះសេចក្តីរាបសាចិត្តស្មោះត្រង់ នៅតែមើលងាយគ្នាបន្ទុះបង្អាប់គ្នា អាងខ្លួនធំដូច្នេះ។ ក៏សេចក្តីទាំងអម្បាលម៉ាននោះ រមែងសាបរលាបសូន្យទៅវិញដែរ ទើបត្រូវបំពេញធម៌ទី៤គឺ **សមានត្តតា** ថែមទៀតឲ្យគ្រប់ចំនួនសង្គហធម៌ ដែលជាចំណងសាមគ្គីទាំង៤ ទើបមនុស្សនិករគ្រប់សញ្ជាតិ អាចមានសន្តានចិត្តទោរទន់រកគ្នា ស្រឡាញ់រាប់រករអឹករអើននិងជួយធ្វើការងារសស្រោកសស្រាំស្រុះស្រួលព្រមៗគ្នា ហើយអាចញុំាងករណីយកិច្ចឲ្យបានសម្រេចយ៉ាងឆាប់រួសរាន់ទាន់ចិត្តនិងបានសេចក្តីសុខចម្រើនអស់កាលជាយូរជាអង្វែងទៅ។ ព្រះភគវន្តមុនីនាថបរមគ្រូទ្រង់ត្រាស់ថា មាតាបិតា សង្គ្រោះបុត្តធីតា គ្រូអាចារ្យសង្គ្រោះសិស្សានុសិស្ស ឥស្សរជនមានព្រះរាជាជាដើម សង្គ្រោះប្រជាពលរដ្ឋទូទៅ សប្បុរសទាំងឡាយមានព្រះពុទ្ធអង្គជាដើម សង្គ្រោះសាវកសាវិកា ឲ្យតាំងនៅក្នុងសម្មាបដិបទា បែបនេះបាននាមថា "បុព្វការី"

ជាធំជាទីគោរពកោតក្រែង ជាទីស្រឡាញ់រាប់អាន ជាទីពឹងពំនាក់របស់បុត្ត ធីតា សិស្សានុសិស្ស ប្រជាជនទូទៅនិងពុទ្ធបរិស័ទទាំងឡាយ ជនទាំងអស់នោះ សោតក៏ត្រូវតែធ្វើបដិការតបគុណវិញ ព្រោះថា "បុព្វការីជន" ជាជនជាន់ខ្ពស់ ជាបុញ្ញក្ខេត្ត ជាបុគ្គលគួរទទួលបដិការគុណអំពីកតញ្ញូជនវិញរកទីបំផុតគ្មាន។ អ្នកទាំងឡាយគួរបំពេញសង្គហវត្ថុទាំង៤ប្រការនេះឲ្យបានបរិបូណ៌គ្រប់សព្វចុះ អ្នកនឹងបានដល់នូវនាទីជាជនជាន់ខ្ពស់ឧត្តមបំផុតជនជាន់ក្រោយ គ្រាន់បានជាទីស្រោចស្រង់គ្នាតៗទៅឲ្យមានសាមគ្គីភាពទាំងនាំឲ្យបានសេចក្តីសុខសាន្តគ្រប់ៗគ្នាទៅមុខ ប្រកបជ័យជោគក្នុងឥធលោកនិងបរលោកពុំខានឡើយ។

មានពាក្យចោទថាៈ ចុះចំណងសាមគ្គីទាំង៤នោះតើឈ្មោះអ្វីខ្លះ?

ឆ្លើយៈ ចំណងសាមគ្គីទាំង៤នោះគឺ **១-ទានៈ ២-បេយ្យវជ្ជៈ ៣-អត្ថចរិយា ៤-សមានត្តតា** ដូច្នេះឯង។ ចុះទានៈ អធិប្បាយដូចម្តេច? ចូរប្រែហើយអធិប្បាយមកមើល? ទានៈ ប្រែថាឲ្យ, ថាបូជា, ថាជូន, ថាផ្តល់នូវសម្បត្តិទ្រព្យទាំងពួង មានសំពត់អាវសារស្បៃត្រៃចីវរ បិណ្ឌបាតជាដើមដល់អ្នកដទៃមានមាតាបិតាជាអាទិ៍ ឈ្មោះថា **ទានៈ** ទាននេះមាន២យ៉ាងគឺៈ ឲ្យចំពោះបុគ្គលម្នាក់ៗដោយសេចក្តីស្រឡាញ់រាប់អាន ដូចជូនចំពោះមាតាបិតាឬមាតាបិតាឲ្យទ្រព្យដល់កូនកម្លោះក្រមុំចាយវាយ ស៊ីចុកស្លៀកពាក់

លោកគ្រូឲ្យកូនសិស្សរបស់ខ្លួន នាយថៅហ្វាយឲ្យដល់ញាតិមិត្តកម្មករ ដោយយោគយល់យ៉ាងនេះហៅថា **បដិបុគ្គលិកទាន ឬ អសាធារ-ណទាន** ព្រោះជាទានសង្គ្រោះចំពោះបុគ្គលម្នាក់ៗ។ ឲ្យទ្រព្យសម្បត្តិមិនចំពោះ ដូចស្ថាបនាសាលារៀន ជីកស្រះ អណ្តូង សាងមន្ទីរពេទ្យ សាងកុដិ សាលា វិហារ សម្រាប់ប្រជាជននៅអាស្រ័យរៀនសូធ្យឬសម្រាប់បព្វជិតទូទៅ យ៉ាងនេះហៅថា **សង្ឃគតាទាន ឬ សាធារណទាន** ព្រោះជាទានថ្លៃថ្នូរឧត្តុង្គឧត្តមប្រសើរណាស់ តែងផ្សាយសេចក្តីសុខដល់មហាជនជាសាធារណ៍មិនចំពោះឡើយ។

លោកអ្នកប្រាជ្ញពិចារណាឃើញថា បដិបុគ្គលិកទានឬអសាធារណទាននោះឲ្យលទ្ធផលផ្តល់សេចក្តីសុខតូចតាចពេក មិនស្មើដល់ផលសង្ឃគតាទានឬសាធារណទាន ទើបលោកលះបង់សុខតូច ប្តូរយកសុខដ៏ធំទូលាយវិញ សមដូចព្រះពុទ្ធភាសិតថាៈ

**មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**[១]

**ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ។**

អ្នកប្រាជ្ញបើឃើញសុខធំទូលាយ ព្រោះតែលះសុខតូចតាចចេញ ទើបលោកលះសុខតូចតាចនោះ ហើយប្តូរយកសុខធំទូលាយវិញ។ ម្យ៉ាង

១–បកិណ្ណកវគ្គ អត្តនោបុព្វកម្មវត្ថុ ធម្មបទ ភ.៧ ទំព័រ១៨៧។

ទៀតសិស្សានុសិស្ស បុត្តធីតា ញាតកាឬកម្មករក្នុងចំណោមពុទ្ធបរិស័ទ អ្នកមានចិត្តកតញ្ញូកតវេទី លះទ្រព្យធ្វើបដិការៈតបគុណចំពោះមាតាបិតា, គ្រូអាចារ្យ, នាយចៅហ្វាយឬបូជាព្រះរតនត្រ័យយ៉ាងនេះជាទានខ្ពង់ខ្ពស់បំផុត គួរបណ្ឌិតទាំងឡាយ រំពឹងជញ្ជឹងមើលតាមព្រះពុទ្ធភាសិតនេះផងចុះ។ គួរយកតម្រាប់ឃ្មុំ កុំយកតម្រាប់ក្តែញាំង ក្តែញាំងវាមានព្យាយាមខ្លាំងណាស់ដែរ វាខំធ្វើសំបុកវានៅ ប៉ុន្តែខំប្រឹងប្រែងតែម្នាក់ឯង ប្រឹងពាំនាំយកដីភក់មកធ្វើជាសំបុកបានតូចៗ នៅចុះតែខ្លួនឯងនិងកូនមួយពីរប៉ុណ្ណោះបាននៅជាសុខដែរ តែបានសុខតូចតាចពេក មិនស្មើដល់ឃ្មុំៗ វានាំគ្នាព្យាយាមហើរទៅពាំនាំយកទឹកផ្អែមអំពីព្រៃឈើ អំពីស្រះគ្រប់តំបន់ស្រុះគ្នាណាស់ ឥតមានប្រចាំគ្នាបន្តិចឡើយ ចេះតែហើរចេញទៅមកព្រោងព្រាត ធ្វើការធ្មៀលធ្មាត់ ខ្លះទៅខ្លះមកគ្មានឈប់ឈរ តែងធ្វើលំនៅបានធំៗ ផ្ទុកកូនចៅជៅសន្តានបានចំនួនច្រើនគ្នា បានសុខសប្បាយសាយភាយទាំងហ្វូង។ យ៉ាងនេះមុខគួរឲ្យសរសើរណាស់ បានជាលោក អ្នកប្រាជ្ញ តែងធ្វើទានណាដែលបានសុខសប្បាយដល់មហាជនទូទៅច្រើនរូបដូច្នោះឯង។ លុះដល់វេលាដែលលោកទទួលលទ្ធផលវិញ ក៏ធំទូលាយណាស់ដែរ គឺបានលាភសក្ការៈនិងសេចក្តីសរសើរ ក្នុងលោកនេះនិងលោកខាងមុខដ៏ក្រៃលែងទៀត។

ការវិសជ្ជនាដោះស្រាយមកក្នុងសង្គហៈទី១ដោយសង្ខេបប៉ុណ្ណេះ។

ចុះ បេយ្យវជ្ជៈ ទី២នោះតើប្រែដូចម្ដេច? អធិប្បាយយ៉ាងណា? ចូរដោះស្រាយមកមើល។

ឆ្លើយៈ បេយ្យវជ្ជៈ ប្រែថា ពោលពាក្យជាទីគាប់ចិត្តគឺនិយាយសម្ដីពីរោះផ្អែមល្ហែមចំពោះមាតាបិតាជាអាទិ៍ ទាំងនាំឲ្យអ្នកស្ដាប់រីករាយជាប់ចិត្ត បានស្ដាប់កាលណាក៏ញ៉ាមចង់តែស្ដាប់ទៀត។

បេយ្យវជ្ជៈ នេះមាន២យ៉ាងគឺ ១-បិយវាចា បានខាងវាចាពីរោះទន់ភ្លន់ ជាទីជាប់ចិត្តអ្នកស្ដាប់។ ២-អត្ថសញ្ហិតាវាចា បានខាងវាចាប្រកបដោយប្រយោជន៍។ អ្នកឆ្លៀសវៃខាងវោហារ តែងហៅរកគេដោយពាក្យបោរីភាពថា លោកតា, លោកឪពុក, លោកយាយ, លោកម្ដាយ, លោកបង, លោកប្អូន, លោកកូន, លោកក្មួយ, លោកចៅ, លោកមីង, លោកពូ, លោកអ៊ុំ, អ្នកនាងជាដើម ដឹងទាបខ្ពស់ តាមជាន់ ឋានៈ ដូច្នេះគួរជាទីស្រឡាញ់ពេញចិត្តដល់អ្នកស្ដាប់ លុះស្ដាប់ហើយអាចជួយធ្វើការងារមិនខ្លាចនឿយហត់ឡើយ ដូចជាគោនន្ទវិសាលបានស្ដាប់ឮសម្ដីព្រាហ្មណ៍ជាម្ចាស់សរសើរ ហៅរកដោយពាក្យថា កូនប្រុសអញល្អណាស់ កូនអញខ្លាំងពូកែណាស់ កូនអញស្លូតត្រង់ណាស់ ម្ល៉ោះហើយគោនន្ទវិសាលត្រេកអរមានកម្លាំងអាចអូសរទេះដែលចងភ្ជាប់គ្នាទាំង៥០០គ្រឿងឲ្យឈ្នះ ពួក

គោភ្នាល់ទាំងប៉ុន្មាន ធ្វើឲ្យព្រាហ្មណ៍ជាម្ចាស់បានប្រាក់ទាំងពាន់កហាបណៈផង ទាំងខ្លួនឯងក៏មានចិត្តសោមនស្សរីករាយ ដោយសារបានសងគុណម្ចាស់ផង។ នេះបានខាងចៅហ្វាយនាយចេះនិយាយ លួងលោមយកចិត្តអ្នកនៅក្រោមបង្គាប់ ឲ្យមានកម្លាំងធ្វើការងារ ឲ្យបានសម្រេចដូចគោលបំណង យ៉ាងនេះហៅថា **បិយវាចា**។ ឯវាចាប្រកបដោយប្រយោជន៍នោះគឺអ្នកនិយាយចូលចិត្តដាស់គំនិតឲ្យអ្នកស្តាប់ប្រុងចាំស្តាប់ ចូលចិត្តពន្យល់អ្នកស្តាប់ឲ្យឃើញប្រយោជន៍ជាក់ស្តែង គួរតែប្រព្រឹត្តតាមដោយពិត។ ដូចព្រះអានន្ទត្ថេរ បើពុទ្ធបរិស័ទទាំង៤ មានភិក្ខុជាដើមចូលមកបានឮពាក្យអានន្ទត្ថេរហើយ អ្នកស្តាប់ក៏ជ្រះថ្លារីករាយទាំងអស់គ្នា មានវេលាមួយ ព្រះអានន្ទបានបង្រៀនធម៌ដល់ស្រីស្នំ៥០០រូបនៃព្រះបាទបសេនទិ-កោសល ពួកស្ត្រីទាំងនោះជ្រះថ្លាប្រគេនសំពត់ល្អៗ មានសាច់ម៉ដ្ឋ ចំពោះព្រះអានន្ទត្ថេរចំនួន៥០០ផ្ទត់ដែរ។ លុះដល់ស្ត្រីទាំងនោះឡើងគាល់ព្រះរាជាៗ ទ្រង់សួរព្រោះមិនឃើញសំពត់បង់កដល់ម្នាក់សោះ ស្ត្រីទាំងអស់នោះក្រាបបង្គំទូលថា ខ្ញុំម្ចាស់ប្រគេនព្រះអានន្ទត្ថេរទាំងអស់គ្នាទៅហើយ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះ ក៏កើតទោមនស្សថា មិនគួរបើព្រះអានន្ទហ៊ានទទួលសំពត់ច្រើនរយផ្ទត់ដល់ម្ល៉េះសោះ។ លុះព្រឹកឡើង ព្រះអង្គស្តេចយាងទៅកាន់វត្តជេតពន សំដៅទៅរកព្រះអានន្ទត្ថេរៗ ក៏ធ្វើបដិសណ្ឋារៈ

រាក់ទាក់ដោយថេរវាចាដ៏ពីរោះថា សូមថ្វាយព្រះពរ មហារាជទ្រង់ស្តេច យាងទាំងពេលថ្មើរនេះ តើទ្រង់ព្រួយព្រះរាជហឫទ័យយ៉ាងណា? ព្រះបរមក្សត្រ គ្រាន់តែទ្រង់សណ្តាប់ថេរវាចាព្រះអានន្ទប៉ុណ្ណោះ បែរជាមានព្រះបន្ទូលថា ករុណាលោកម្ចាស់ ខ្ញុំព្រះករុណាមក សូមសួរលោកម្ចាស់ ក្រែងព្រះសម្ពុទ្ធបរមគ្រូទ្រង់បញ្ញត្តឲ្យភិក្ខុប្រើប្រាស់តែចីវរ៣ប៉ុណ្ណោះទេឬ? ដូចម្តេចបានជាលោកម្ចាស់ហ៊ានទទួលសំពត់អំពីស្រីស្នំច្រើនដល់ម្ល៉ោះ តើយកទៅធ្វើអ្វី? មិនខុសនឹងពុទ្ធប្បញ្ញត្តិហើយឬ? ព្រះអានន្ទត្លេរតបថា បពិត្រមហារាជ សូមព្រះអង្គទ្រង់សវនាការដោយគោរពចុះ អាត្មាភាពសូមថ្វាយព្រះពរដូចមានតទៅៈ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តភិក្ខុប្រើប្រាស់តែចីវរ៣ប្រដាប់ ក៏ពិតមែនហើយ តែព្រះអង្គឥតមានបញ្ញត្តហាមត្រង់ទទួលវត្ថុទានប៉ុន្មានៗនោះក៏ទេដែរ បានជាអាត្មាភាពអាចហ៊ានទទួលសំពត់ច្រើនដល់ម្ល៉ោះ ដើម្បីរក្សាសទ្ធាទាយកអ្នកប្រគេនប៉ុណ្ណោះទេតើ។ ឯអាត្មាភាពបានទទួលសំពត់៥០០ផ្ទត់នោះមក អាត្មាភាពប្រគេនទៅព្រះសង្ឃដែលមានចីវរចាស់ៗប្រមាណ៥០០អង្គអស់ទៅហើយ សូម្បីព្រះសង្ឃដែលបានសំពត់ថ្មីៗមក លោកក៏យកសំពត់ចីវរចាស់ទៅធ្វើកម្រាល ហើយយកកម្រាលចាស់ពីមុនទៅធ្វើជាទ្រនាប់ជូតជើងខ្លះ យកទៅចិញ្ច្រាំលាយដីស្អិតបូកកុដិខ្លះ។ ព្រះថេរៈទាំងនោះមានសេចក្តីត្រេកអរណាស់ តែងខំប្រឹងធ្វើ

សង្ឃក្ករណីយកិច្ចសព្វអន្លើទាំងខំព្យាយាមធ្វើសមណធម៌គ្រប់អង្គផង សូមព្រះអង្គទ្រង់ជ្រាប។ លុះព្រះរាជាទ្រង់ព្រះសណ្ដាប់ថេរវាចារបស់ព្រះអានន្ទត្ថេរហើយ ទ្រង់ព្រះតម្រិះថា ឃីអើ! ពីរោះអីពីរោះម្ល៉េះ។ ព្រះមហាក្សត្រទ្រង់ជ្រះថ្លាក៏ប្រើរាជបុរសឲ្យទៅនាំយកសំពត់ដែលមានសាច់ម៉ដ្ឋ ប្រមាណ ៥០០ផ្ទត់ពីក្នុងរាជវាំង មកប្រគេនព្រះអានន្ទត្ថេរទៀត ទើបទ្រង់យាងចូលកាន់ព្រះរាជវនិវេសនដ្ឋានវិញ ទ្រង់ដាស់តឿន រាជបរិស័ទឲ្យស្ដាប់ធម៌ព្រះអានន្ទត្ថេរគ្រប់ៗគ្នាព្រមទាំងសរសើរថា មានប្រយោជន៍ណាស់។ អ្នកស្ដាប់ទាំងឡាយមិនចេះឆ្អែតនឹងថេរវាចារបស់ព្រះអានន្ទឡើយ ព្រោះហេតុនោះសប្បុរសអ្នកឲ្យទាន ត្រូវពោលពាក្យពីរោះជាទីស្រឡាញ់រាប់អានផង ទើបចងមិត្តមេត្រីភាពបានស្ថិតស្ថេរ។ បើគ្រាន់តែឲ្យប្រាក់មាសចាយវាយគរគោកហើយ ប៉ុន្តែនិយាយច្រគោះខ្មោះខ្មូរតាមក្រោយទៅ មុខជានឹងបែកសាមគ្គី យ៉ាងឆាប់រហ័សមិនខានឡើយ។ ការវិសជ្ជនាដោះស្រាយមកក្នុងសង្គហវត្ថុទី២ដោយសង្ខេបប៉ុណ្ណេះ។

ចុះ អត្ថចរិយា ទី៣នោះ តើប្រែស្រាយដូចម្ដេច? ចូរប្រែហើយអធិប្បាយឲ្យងាយស្ដាប់មកមើល?

ឆ្លើយថាៈ អត្ថចរិយា ប្រែថា ការប្រព្រឹត្តិឲ្យជាប្រយោជន៍គឺធ្វើកិច្ចការជំនួសមាតាបិតា នៅវេលាគួរឬជួយកិច្ចធុរៈដល់គ្នានិងគ្នា ក្នុងគ្រាដែល

មានអាសន្ន ហៅថា **អត្ថចរិយា** បុគ្គលបើគ្រាន់តែឲ្យទាននិយាយពាក្យពីរោះប៉ុណ្ណោះ ប៉ុន្តែមិនជួយការពារផលប្រយោជន៍ដល់គ្នានិងគ្នាផងទេ សេចក្តីស្និទ្ធស្នាលក៏គង់រយាលទៅដែរ ហេតុនេះ ទើបត្រូវបំពេញ **អត្ថចរិយា** ជាសង្គហធម៌ទី៣នេះទៀត។ **អត្ថចរិយា** ចែកចេញជា២យ៉ាង គឺ **វេយ្យាវច្ច:** ការជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈ ដរាបដល់បានសម្រេច១។ **សមានបជា** ការដឹកនាំក្នុងផ្លូវធម៌១។

(ក) **វេយ្យាវច្ច:** មានឧទាហរណ៍ដូចមាតាបិតាខ្វល់ខ្វាយធ្វើកិច្ចធុរៈផ្គត់ផ្គង់ឲ្យបុត្តធីតា ដូចបានឲ្យទទួលការសិក្សា ឲ្យតាំងគ្រួសារនិងគេហស្ថានទីលំនៅជាដើមក្តី ឯបុត្តធីតាបានជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតាវិញក្តី។ ឥស្សរជនបានជួយកិច្ចធុរៈ ដូចបានពណិនាហើយខាងដើមដល់អ្នកពឹងពាក់ ដោយបានព្យាបាលនៅវេលាឈឺថ្កាត់ឬទំនុកបម្រុងឲ្យមានកើរ្តិឈ្មោះយសស័ក្តិប្រាកដក្នុងប្រជុំជនក្តី ប្រជាពលរដ្ឋសោត បានតាំងចិត្តជួយធ្វើការរបស់ឥស្សរជន ឲ្យសម្រេចតាមគោលបំណងរបស់លោក ព្រមទាំងខ្លួនឲ្យលោកជឿជាក់ទុកចិត្តបាន ល្មមជាទីស្រឡាញ់ពេញចិត្តរបស់លោកក្តី។ មិត្តសម្លាញ់ ជួយខ្វល់ខ្វាយកិច្ចធុរៈរវាងគ្នានិងគ្នាទៅវិញទៅមកដោយកម្លាំងកាយខ្លះ កម្លាំងវាចាខ្លះ កម្លាំងចិត្តខ្លះ ឲ្យសមតាមពុទ្ធភាសិតថា **អត្ថម្ហិ ជាតម្ហិ សុខាសហាយា** ប្រែថាៈ កាលណាមានប្រ-

យោជន៍កើតឡើងដល់ខ្លួន មិត្តសម្លាញ់ទាំងឡាយរមែងជួយឲ្យបានសេចក្តីសុខក្តី ទាំងអស់នេះឈ្មោះថា វេយ្យាវច្ចៈ ឯការមេត្រីរាប់អានគ្នាយ៉ាងជិតស្និទ្ធបាននោះ គឺជួយកិច្ចធុរៈរវាងគ្នានិងគ្នាតាមលំដាប់សង្គមញាតិ ទៅពីដំបូងទើបរាប់រកគ្នារស់នៅបានយឺតយូរ បើទុកជាសង្គមញាតិមានពូជពង្សសាច់ឈាមជាប់គ្នាក៏ដោយ ប៉ុន្តែបើមិនដែលបានជួយកិច្ចធុរៈគ្នាដល់ម្តងណាទេ ក៏មិនអាចនឹងបានស្និទ្ធស្នាលយូរប៉ុន្មានដែរ មិនស្មើនឹងបានជួយកិច្ចធុរៈគ្នាឡើយ សមដូចពុទ្ធភាសិត១បទទៀតថា **វិស្សាសា បរមាញាតី** ការស្និទ្ធស្នាលរាប់អានគ្នាទុកថាជាញាតិដ៏ប្រសើរ។

(៤) សមានត្តតា ការដឹកនាំក្នុងផ្លូវធម៌នោះ មានឧទាហរណ៍ដូចជាយើងបបួលគេឲ្យសិក្សាធម៌អាថ៌ឬនាំឲ្យសាងកុសលណាមួយ ឲ្យស្រុះគំនិតព្រមគ្នា មានសាមគ្គីនឹងគ្នា ជាមិត្តមេត្រីតទៅ គឺដឹកនាំអ្នកឥតមានសទ្ធាឲ្យមានសទ្ធាឡើង អ្នកឥតមានសីលឲ្យមានសីលឡើង អ្នកដែលកំពុងឈ្លក់លង់ក្នុងអបាយមុខ៤យ៉ាងគឺលង់នឹងស្រី, លង់នឹងស្រា, លង់នឹងល្បែងពាលា, លង់នឹងបាបមិត្ត ដឹកនាំគ្នាឲ្យលះបង់អបាយមុខនោះៗចេញ ទាំងអស់នេះឈ្មោះថា សមានត្តតា ការប្រព្រឹត្តិប្រយោជន៍ដែលធ្វើឲ្យសមដល់កាលៈទេសៈ ដល់បុគ្គលគ្រប់ជាន់ថ្នាក់ ឲ្យបានសម្រេចសុភមង្គលដូចបានវិសជ្ជនាដោះស្រាយមកក្នុងសង្គហៈទី៣ដោយសង្ខេបតែប៉ុណ្ណោះ។

ចុះ **សមានត្តតា** ទី៤នោះ តើប្រែស្រាយដូចម្ដេច? ចូរប្រែហើយអធិប្បាយមកមើល?

ឆ្លើយថាៈ **សមានត្តតា** ប្រែថា ការប្រព្រឹត្តិបន្ទាបបន្ទន់ មិនធ្មើងធ្មៃ, មិនប្រកាន់ខ្លួន, មិនវាយឫកខ្ពស់ពេក ដូចមានអធិប្បាយតទៅថាៈ ការចែកធនធានឲ្យ ការនិយាយពាក្យពីរោះផ្អែមល្ហែមនិងជួយខ្វល់ខ្វាយធ្វើកិច្ចធុរៈគ្នានិងគ្នាប៉ុណ្ណោះពិតមែនហើយ ប៉ុន្តែបើមិនចេះរៀបចំខ្លួនឲ្យសមរម្យដល់មាឌ បែរជាវាយឫកក្រអឺតក្រអោង ដូចសុភាសិតថាៈ *បង់បោយមិនមើលប្រាណ ដាំចង្ក្រានមិនប្រមាណឆ្នាំង* ដូច្នេះវិញ សេចក្ដីរាប់អានគ្នានោះក៏គង់រយាលទៅវិញដែរ លុះតែសេចក្ដីប្រព្រឹត្តិល្មមគួរដល់មាឌផង ទើបការស្និទ្ធស្នាលនោះកាន់តែរឹងប៉ឹងឡើង ហើយតាំងនៅជាស្ថាពរ បានហេតុនេះត្រូវបំពេញ **សមានត្តតា** សង្គហវត្ថុទី៤នេះទៀត។ **សមានត្តតា** ប្រែថា ភាពជាអ្នកស្មើមានអាកប្បកិរិយារាបសាក្នុងធម៌នោះៗ។ **សមានត្តតា** ចែកចេញជា២យ៉ាងគឺៈ **បុគ្គលាធិដ្ឋាន** មានបុគ្គលជាទីតាំង១។ **ធម្មាធិដ្ឋាន** មានធម៌ជាទីតាំង១។

(ក) **បុគ្គលាធិដ្ឋាន** មានឧទាហរណ៍ថា សូម្បីញាតិមានសភាពថោកថយជាង ឯចំណែកខាងខ្លួនមានគុណវិសេសខ្ពង់ខ្ពស់ដោយឥស្សរិយយស ដោយភោគសម្បត្តិ ដោយបរិវារ ក៏មិនត្រូវធ្វើមានះក្អេងក្អាងប្រមាថ

មើលងាយឡើយ ត្រូវតែធ្វើឥរិយាទន់ភ្លន់ឱនលំទោន សំពះគំនាប់ដល់ញាតិដែលមានវ័យចម្រើនជាដរាប គឺពីដើមមកធ្លាប់មានការរាប់អានយ៉ាងណា ក្រោយមកក៏ត្រូវតែរាប់អានយ៉ាងនោះ។ លុះញាតិទាំងឡាយបានទទួលការគោរពកោតក្រែងយ៉ាងនោះហើយ រមែងស្រឡាញ់ចូលចិត្តសម្ដែងសេចក្ដីស្និទ្ធស្នាលតបវិញ អាចធ្វើសាមគ្គីធម៌ឲ្យកាន់តែមាំឡើងវង្សត្រកូលនោះរមែងតាំងនៅជាសង្គមជាក្រុមធំ ជាសង្គ្រោះសមាគមនៅយឺនយូរទៅបាន នេះជាសមានត្តតាក្នុងធម៌។ ឯ **អបចាយនៈ** មានសេចក្ដីស្រដៀងគ្នា បានខាងការគោរពកោតក្រែងទូទៅចំពោះញាតិសាលោហិត មិត្តសម្លាញ់ ដែលស្មើគ្នាដោយជំនាន់ក្ដី ក៏សម្ដែងសេចក្ដីរាប់អានគ្នាដោយពេញចិត្ត មិនមើលងាយគ្នា ទោះញាតិដែលជាអ្នកធំក្ដី អ្នកតូចក្ដី ក៏ត្រូវធ្វើសេចក្ដីស្និទ្ធស្នាលទៅមក មានសេចក្ដីស្មោះស្មើចំពោះញាតិនោះៗ រមែងញ៉ាំងសុខសាន្តឲ្យកើតមានទូទៅគ្រប់ៗគ្នា។ ព្រះបរមគ្រូទ្រង់ត្រាស់ថាៈ **ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ** អ្នកប្រាជ្ញមានការនៅរួមរស់ជាមួយរមែងនាំមកនៅសេចក្ដីសុខសប្បាយ ដូចបាននៅជួបជុំគ្នានៃពួកញាតិដូច្នោះដែរ កល្យាណជនអ្នកធ្លាប់រាប់អានគ្នាយ៉ាងណា មិត្តម្ខាងក៏មិនរវាតបែកចេញពីគ្នាដោយសារការទាក់ទងនោះឡើយ គង់តែនៅរាប់អានដដែល មិត្តម្ខាងទៀតដែលធ្លាប់រាប់អានតាមទម្លាប់ពីដើមមកក៏មិនប្រែប្រួល មិត្តទាំងពីរ

ខាងតែងបានរក្សានូវសាមគ្គីមិត្តឲ្យមាំមួនជាស្ថាពរតទៅ សូម្បីមិនមែនញាតិសាលោហិតសោះ គង់មានសមានត្តតាធម៌នោះ អាចញ៉ាំងប្រយោជន៍ឲ្យសម្រេចដូចគ្នា យ៉ាងនេះជាបុគ្គលាដ្ឋាន មានបុគ្គលជាទីតាំង។ (ខ–ធម្មាធិដ្ឋាន មានឧទាហរណ៍ថា: ជនអ្នកតាំងនៅក្នុងគុណធម៌ ដូចពួកបព្វជិតរមែងតាំងនៅបានដោយអំណាចមានសីលធម៌ស្មើគ្នា បើមិនមានសីលធម៌មិនមានការព្រមព្រៀងគ្នាទេ ចេះតែប្រណាំងប្រជែងប្រកាន់មានះតែរៀងខ្លួន ក្រៅពីសីលធម៌ហើយសាមគ្គីបព្វជិតដូចគ្នា ក៏មិនអាចតាំងនៅបានឡើយ ព្រោះហេតុនោះ លោកដែលជាប្រធាននៃគណៈសង្ឃក្នុងសង្គមវត្តនីមួយៗ ត្រូវព្យាយាមបំភ្លឺពន្យល់អំពីផលនៃសាមគ្គីធម៌និងទោសនៃការបែកសាមគ្គី ឲ្យសព្រហ្មចារីជនបានស្ដាប់រឿយៗ ដើម្បីនិយមធ្វើតាមសណ្ដាប់ធ្នាប់របស់សង្គមវត្តនោះៗក្នុងឋានៈជាឧត្តមគតិ ទាំងដើម្បីរក្សាសាមគ្គីឲ្យរឹងប៉ឹងពេញជំហរឡើង យ៉ាងនេះចាត់ជាធម្មាធិដ្ឋាន មានធម៌ជាទីតាំង)។

សមានត្តតាធម៌នេះ រមែងយឹតយោងបុគ្គលឬគណៈនិងសង្ឃនោះៗឲ្យតាំងនៅក្នុងធម៌សាមគ្គីបាន សង្គហវត្ថុទាំង៤ប្រការ ដែលបានពណ៌នាមកនេះ រមែងចងសាមគ្គីរបស់សាធារណជនក្នុងពិភពលោក ឲ្យខ្ជាប់ខ្ជួនឲ្យប្រព្រឹត្តទៅមូលត្រកូលគ្នាដូចជាភ្លៅរថ ជាស្នូលញ៉ាំងរថឲ្យវិលទៅមក

ដូច្នោះឯង។ ប្រសិនបើមិនមានជនណាបានបំពេញនូវសង្គហវត្ថុទាំង៤នេះទេ គឺថាមិនមាននរណាអើពើនឹងនរណាឡើយ សូម្បីមាតាបិតាបើមិនអើពើនឹងសង្គ្រោះបុត្តធីតាទេ នោះក៏មិនអាចនឹងបានទទួលបដិការគុណ តបអំពីបុត្តធីតាដែរ។ ញាតិមិត្តនាយថៅហ្វាយបើមិនអើពើនឹងបរិវាររបស់ខ្លួនទេ ក៏មិនអាចនឹងបានទទួលបរិវារសម្បត្តិដែរ លុះវេលាខ្លួនមានទុក្ខធុរៈភ័យអាសន្នមកដល់ ក៏រកគ្នីគ្នាជួយមិនបាន នឹងសោយវេទនាតែម្នាក់ឯងជិតដល់ស្លាប់ លុះស្លាប់ទៅហើយក៏ទៅរងទុក្ខក្នុងអបាយភូមិថែមទៀត ដូចរឿងអានន្ទសេដ្ឋី គាត់មានសេចក្តីកំណាញ់មិនចំណាយទ្រព្យធ្វើបុណ្យឲ្យទានដល់អ្នកកម្សត់ទុគ៌តណាសោះ លុះស្លាប់ទៅៗកើតក្នុងត្រកូលចណ្ឌាលអ្នកទំលក្ររហេមរហាមចិញ្ចឹមជីវិតបានដោយលំបាកពេក ម្តាយទ្រាំមិនបានយកទៅបោះចោលលើគំនរសម្រាម ដោយនឹកឃើញថា តែទុកកូនឲ្យនៅជាប់ជាមួយនឹងខ្លួន មុខជាស្លាប់ទាំងខ្លួនឯងផង ព្រោះតែបាបកម្មរបស់កូននេះ[១]។ មានរឿងតោទេយ្យព្រាហ្មណ៍ម្នាក់ទៀត គាត់នៅអាស្រ័យក្នុងតុទិគ្រាម ជិតក្រុងសាវត្ថី គាត់មានទ្រព្យច្រើនប្រមាណ៤៥កោដិ ប៉ុន្តែគាត់ជាអ្នកកំណាញ់ស្វិតស្វាញ មិនដែលរំលែកទ្រព្យចែកទានដល់នរណាសោះ តែងទូន្មានបុត្តធីតាថា កុំឲ្យៗទ្រព្យសម្បត្តិទៅនរណាៗឡើយ ហើយ

១–ធម្មបទដ្ឋកថា បុព្វភាគ ភាគទី៣ ទំព័រ២០២។

គាត់បានកប់ទ្រព្យទុក៤រណ្ដៅ ស្បែកជើងមាស១សែនដំឡឹង១រណ្ដៅ ភាជន៍មាស១សែនដំឡឹង១រណ្ដៅ រូបកហាបណៈ១សែន១រណ្ដៅដែរ គាត់មិនប្រាប់ដល់បុត្តធីតាណាម្នាក់ឡើយ លុះដល់ថ្ងៃស្លាប់ ដោយវង្វេងស្មារតីហើយ ក៏ទៅកើតជាសុនខក្នុងផ្ទះរបស់ខ្លួននោះដោយបាបកម្ម គឺកំណាញ់ស្វិតស្វាញនោះឯង[១]។ និទានដែលសម្ដែងបំភ្លឺប៉ុណ្ណេះ សូមវិញ្ញូជនជាសប្បុរសខំលះកាត់សេចក្ដីកំណាញ់ចេញឲ្យបាន ហើយបំពេញសង្គហវត្ថុទាំង៤នេះ ឲ្យបានគ្រប់គ្រាន់ឡើង ដើម្បីចងសាមគ្គីរួបរួមមិត្តសម្លាញ់ក្នុងសង្គម ទោះគណៈសង្ឃឬគ្រហស្ថក្ដី ឲ្យបានសុខភាពនិងវឌ្ឍនភាព ជាទីរីករាយសប្បាយរវាងគ្នានិងគ្នា ព្រមទាំងជួយទុក្ខធុរៈគ្នា តាំងពីឥឡូវនេះទៅ រហូតដល់អនាគត ក៏នឹងបានរីករាយសប្បាយក្នុងស្ថានសួគ៌ដរាបដល់ព្រះនិព្វាន។

សាធុសប្បុរសទាំងឡាយ! វិញ្ញូជនជាន់មុនលោកបានបំពេញនូវសង្គហធម៌ទាំង៤យ៉ាង តាមសមគួរដល់កម្លាំង លុះលោកមានភ័យអាសន្នកើតឡើងមួយដងមួយកាល សឹងមានញាតិសន្ដានជួយឈឺឆ្អាល ជួយការពារ ជួយព្យាបាលរោគច្រើនឈ្មួចរតិកកងរំពង ឧបសគ្គនិងសត្រូវជងទាំង

១–សុភសូត្រទី១០ ទីឃនិកាយ សីលក្ខន្ធវគ្គ ភាគ១៥ ទំព័រ១៦១ ព្រមទាំងអដ្ឋកថា សុមង្គលវិលាសិនី ទំព័រ៤៣៧ ដែលថ្លែងពីតោទេយ្យព្រាហ្មណ៍ទៅកើតជាឆ្កែជាអាទិ៍។

ពួង មិនអាចមកបៀតបៀនជិតប្រាណលោកបានដោយងាយឡើយ។ នេះឯងជាផលនៃសង្គហវត្ថុដែលលោកបានបំពេញនោះ  ដល់ទម្លាយសង្ខារហើយ  តែងទៅកើតក្នុងសួគ៌ាល័យរីងរឹតតែរីករាយសប្បាយដ៏ក្រៃលែងក្នុងទេវលោកទៀត។ ញាតិមិត្តនិងបរិវារដែលនៅឯមនុស្សលោកនេះ គេនាំគ្នាស្តាយស្រណោះឥតស្រាកស្រាន្ត អ្នកខ្លះនាំគ្នាចារឹកព្រះនាមស័ក្តិយសទុកជាទិដ្ឋានុគតិ ជាឧត្តមប្រយោជន៍ដល់បច្ឆាជនតាជាន់ក្រោយ សូម្បីពួកមិត្តនិងបរិវារក្នុងឆកាមាវចរសួគ៌ ក៏នាំគ្នាហែហមជាឱឡារិកទៀត។ ចូរមើលជាតកព្រះនេមិរាជជាដើមជងចុះ  កាលដែលព្រះបរមពោធិសត្វកំពុងសាងអធិដ្ឋានបារមីនោះ។

**ចប់សង្គហវត្ថុ**

# សម្បទាកថា

តាមយោបល់យល់ឃើញថា បើប្រសិនជាសប្បុរសពុទ្ធបរិស័ទទាំងឡាយបានបំពេញសង្គហវត្ថុទាំង៤ប្រការ ប្រកបដោយសទ្ធានិងបញ្ញាគ្រប់អន្លើ ដូចបានពណ៌នាមកខាងលើហើយ នឹងត្រូវបានទទួលសម្បទាទាំង៧ប្រការជាផលានិសង្សពុំខានឡើយ។

## សម្បទាទាំង៧ប្រការនោះគឺ:

១–អាយុសម្បទា បានអាយុយឺនយូរអង្វែងអស់កាលកំណត់ជាសម្បទ័។

២–រូបសម្បទា មានរូបរាងល្អពេញលេញគ្រប់លក្ខណៈ ជាសម្បទ័។

៣–អារោគសម្បទា មិនមានរោគាពាធផ្សេងៗ ជាសម្បទ័។

៤–អានុភាវសម្បទា មានឫទ្ធិអំណាចមិនមាននរណាហ៊ានទទឹងជាសម្បទ័។

៥–ភោគសម្បទា មានភោគសម្បត្តិបរិបូណ៌មិនទ័លឡើយ ជាសម្បទ័។

៦–បរិវារសម្បទា មានមិត្តភ័ក្តិចោមរោមហែហមជាកិត្តិយស ជា

សម្ប័ទ។

៧–បញ្ញាសម្បទា មានប្រាជ្ញាបរិបូណ៌សម្រាប់ត្រុះផ្លូវលោកិយ លោកុត្តរៈ ជាសម្ប័ទ។

ឧទាហរណ៍ក្នុងបច្ចុប្បន្ននេះ

ដូចជា សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ ដែលទ្រង់មានព្រះរាជហឫទ័យមេត្តាករុណាដល់ប្រជានិករទូទៅ ទ្រង់ដោះទុក្ខប្រជារាស្ត្រឲ្យបានឡើងជាខ្មែរអ្នកជាគ្រប់គ្នានេះ ជាការក្រជាទីបំផុតមិនងាយនឹងមានឥស្សរជនណាក្នុងលោកធ្វើបាន ហើយព្រះអង្គអាចធ្វើបានដោយសន្តិវិធី ដូច្នេះគួរចាត់ចូលក្នុងសង្គហវត្ថុទី១ ដែលហៅថា ទានៈ ឬហៅថា អភយទាន របស់ទ្រង់បាន។

ត្រង់ទ្រង់មានព្រះហឫទ័យយកកតញ្ញូតា ចំពោះបុព្វបុរសរបស់ព្រះអង្គ មានលើករាជសម្បត្តិ ថ្វាយតបព្រះគុណធ្ងន់វិសេសចំពោះព្រះវររាជបិតានិងព្រះវររាជជននីនាថ ព្រះទាំងប្រគេនសមណស័ក្តិដល់ព្រះសង្ឃនិងទ្រង់ព្រះរាជទានស័ក្តិយសដល់មន្ត្រីណា ដែលទ្រាំតស៊ូជាមួយនឹងព្រះអង្គមកនោះ ឲ្យមានអំណាចលើសលែងតាមលំដាប់ហូរហែមកនេះ ជាទានថ្នាក់ខ្ពស់ផ្នែកខាងបូជាសង្គហលក្ខណៈរបស់ទ្រង់ ទានបែបនេះក៏មិនងាយនឹងមាននរជនណាធ្វើបានឡើយ ហើយព្រះអង្គអាចធ្វើបានដោយ

សន្តិភាព នេះគួរឲ្យអស្ចារ្យណាស់។ ទាំងមានព្រះឱង្ការពីរោះក្បោះក្បាយ ផ្អែមល្ហែមប្រកបដោយអង្គអ្នកប្រាជ្ញ៥ប្រការទៀតគឺៈ

១–សុភោ ច ទ្រង់មានព្រះសូរសៀងក្បោះក្បាយឥតអាក់។

២–មហិទ្ធិកោ ច មានព្រះសូរសៀងគួរតែព្រឺស្រៀបកោតខ្លាច អ្នកស្ដាប់នឹងតក់ស្លត់គ្រប់គ្នា។

៣–បរមទ្ធនោ ច មានព្រះសូរសៀងធូន់ៗមុតៗស្មើព្រះខ័នពេជ្រ នាំឲ្យអ្នកស្ដាប់ប្រាប់ទោសខុសឯងៗ គឺដូចជាឃើញទោសកំហុសលាក់បិទ បាំងមិនកើត លាន់ប្រាប់ខ្លួនឯង។

៤–វចនសទ្ធហាភូតោ ច មានព្រះឱង្ការកម្សាន្តព្រហប្ញទ័យទេ ប៉ុន្តែអ្នកស្ដាប់គួរតែជឿជាក់ថា សុទ្ធតែមានប្រយោជន៍ទាំងអស់។

៥–មធុរោ ច បើទុកជាទ្រង់ក្រោធពិរោធនឹងនរណាណាស់ក៏ដោយ ក៏នៅតែមានព្រះសូរសៀង ពីរោះផ្អែមល្ហែមដូចទឹកឃ្មុំ ហើយសុទ្ធតែ ច្បាប់ពិតៗតែម្ដង។

សម្ដេចព្រះបិតាឯករាជ្យជាតិ ព្រះអង្គប្រកបដោយអង្គអ្នក ប្រាជ្ញទាំង៥ប្រការនេះឥតខ្វះមួយឡើយ ត្រង់នេះគួររាប់បញ្ចូលទុកថាជា បេយ្យវជ្ជសង្គហវត្ថុ ទី២ពិត។ មិនតែប៉ុណ្ណោះសោត ទ្រង់មានព្រះ ហឫទ័យស្រោចស្រង់ពន្យល់បំភ្លឺអត្ថប្រយោជន៍ទៀតផង គឺទ្រង់ប្រព្រឹត្តឲ្យ

ជាប្រយោជន៍ទូទៅវែងឆ្ងាយ ដូចជាទ្រង់ដឹកនាំប្រជានិករជាពលរដ្ឋរបស់ព្រះអង្គ ឲ្យចំណាយទ្រព្យធនកសាងសលារៀន សាលាសម្នាក់ សាងស្ពានលើកថ្នល់ ជីកស្រះ ជីកអណ្តូង លើកទ្រនប់ទឹកដើម្បីកសិករធ្វើស្រែចម្ការដាំសួនច្បារ សង់មន្ទីរពេទ្យ ចែកថ្នាំឱសថព្យាបាលរោគដោយកម្លាំងព្រះរាជទ្រព្យនិងដោយកម្លាំងព្រះកាយពល ឥតគិតដល់ការនឿយព្រួយព្រះអង្គឡើយ ទ្រង់ប្រាថ្នាឲ្យប្រជាពលរដ្ឋរបស់ព្រះអង្គចេះធ្វើការ ចេះរកផលប្រយោជន៍ ដើម្បីញ៉ាំងជីវភាពសម្បូរណភាពគ្រប់ៗឋានៈរហូតដល់គណៈរដ្ឋមន្ត្រីអ្នករាជការគ្រប់ប្រភេទអត់ទ្រាំពុំបាន ក៏ឃ្លាតចាកកៅអីចុះទៅជួយធ្វើស្រះអណ្តូងកាប់គាស់ដី រែកដីលើកទ្រនប់ លើកថ្នល់ជាដើម ដោយចិត្តសោមនស្សជ្រះថ្លារីករាយព្រមគ្នា ដល់ត្រឡប់មកពីប្រកបការប្រយោជន៍នោះវិញ ធ្វើមុខញញឹមញញែមស្រស់បំព្រង់អួតប្រាប់គ្នាថា សប្បាយណាស់ គ្មានអស់កម្លាំងទេ ទទួលទានបាយបាន ទទួលដំណេកក៏លក់ស្រួលខ្លួនណាស់ បណ្តារាស្ត្រក៏ចោមរោមស្រឡាញ់រាប់អាន ហើយខ្លាចឯងជាងពីដើមនោះទៅទៀត ខនេះ ដូចជាព្រះអង្គនាំមនុស្សទាំងអស់នោះឲ្យស្រឡាញ់រាប់រកគ្នា ជួយធ្វើការឲ្យជាប្រយោជន៍ដល់គ្នានិងគ្នាដោយសាមគ្គីធម៌យ៉ាងនេះ យើងមានសេចក្តីជឿជាក់និងសេចក្តីសង្ឃឹមថា បើប្រជាពលរដ្ឋនាំគ្នាគោរពប្រតិបត្តិ ហែតាមព្រះរាជនយោបាយដ៏វិសេសសស្រោក

សម្រាំតែយ៉ាងនេះដរាបទៅប្រទេសយើងមុខជាបានសុខសម្បូណ៌ សប្បាយ ចម្រុងចម្រើនតម្រិះវិជ្ជាសព្វគ្រប់ នឹងមានពលភាពពូកែពិតមិនចាញ់ប្រទេសជិតខាងឡើយ ព្រះរាជនយោបាយជួយដឹកនាំប្រជាពលនិករឲ្យបាន សម្រេចយ៉ាងនេះ គួររាប់បញ្ចូលជា អត្ថចរិយា សង្គហវត្ថុទី៣ពិត។

អត្ថចរិយាចែកចេញជា៣ប្រការគឺ:

១–ទិដ្ឋធម្មិកត្ថ: ប្រយោជន៍បច្ចុប្បន្ននេះ។

២–សម្បរាយិកត្ថ: ប្រយោជន៍ទៅបរលោកនាយ។

៣–បរមត្ថ: ប្រយោជន៍ព្រះនិព្វាន។

ក) ប្រយោជន៍បច្ចុប្បន្ននេះចែកចេញជា៤យ៉ាងគឺ:

១–ឧដ្ឋាន: ការប្រឹងរៀន ប្រឹងរក ប្រឹងធ្វើឥតឈប់ឈរ។

២–អារក្ខ: ការរក្សាទ្រព្យដែលបានហើយឬបើចេះដឹងវិជ្ជាផ្សេងៗ ហើយរក្សាទុកឲ្យគង់វង្ស មិនកញ្ចះកញ្ចាយ។

៣–កល្យាណមិត្តតា ភាពជាអ្នកមានមិត្តភក្តិល្អសុចរិតពិតត្រង់ជាគ្នា។

៤–សមជីវិតា ភាពជាអ្នករស់នៅស្មើនឹងកល្យាណជនជងគ្នា។

ទាំង៤នេះហៅថា ទិដ្ឋធម្មិកត្ថប្រយោជន៍ ត្រូវបានក្នុងបច្ចុប្បន្ន។

ខ) ប្រយោជន៍លោកខាងនាយមាន៥ប្រការគឺៈ

១–សទ្ធា សេចក្តីជឿកម្មជឿផលនិងជឿប្រាជ្ញាត្រាស់ដឹងនៃព្រះពុទ្ធ ជឿគុណព្រះធម៌និងព្រះសង្ឃថាជាសរណៈដ៏ឧត្តម។

២–សីលៈ ការប្រព្រឹត្តិកាយវាចាឲបរាសាវៀរចាកទោស។

៣–សុតៈ ការសូត្យស្វាធ្យាយ ស្តាប់ធម៌ច្រើនជាពហុស្សូត។

៤–ចាគៈ ការមិនកំណាញ់ លះទ្រព្យឲ្យទានទុកជាពូជ។

៥–បញ្ញា ធម្មជាតិដឹងច្បាស់ដល់កងសង្ខារឥតសង្ស័យ។

ទាំង៥នេះហៅថា សម្បរាយិកត្ថប្រយោជន៍ ត្រូវបានទៅក្នុងបរលោកនាយ។

គ) ឯបរមត្ថប្រយោជន៍ សំដៅយកស្ថានព្រះនិព្វាន ជាទីសុខក្សេមក្សាន្តផុតចាកលោកតែ១ប៉ុណ្ណោះ។

សម្តេចព្រះបិតាឯករាជ្យជាតិ ព្រះអង្គបានជួយសង្គ្រោះដោះទុក្ខធុរៈដល់មហាជនច្រើនប្រភេទ ឲ្យប្រជាជាតិបានសម្រេចប្រយោជន៍ទាំង៣ប្រការគ្រប់ប្រាណ ដែលរាប់បញ្ចូលថា អត្ថចរិយា គឺៈ ឈ្មោះថាព្រះអង្គទ្រង់បានបំពេញសង្គហវត្ថុទី៣ហើយដោយពេញលេញ។

ហេតុដែលទ្រង់បានសង្គ្រោះប្រជានិករ ដោយចំណងសាមគ្គីធម៌យ៉ាងនេះ ទើបប្រជាជនទាំងឡាយសូម្បីជាតិដទៃ ក៏ចោមរោមស្រឡាញ់

រាប់អានគោរពកោតក្រែងព្រះអង្គ ហើយនាំលាភសក្ការៈ តង្វាយផ្សេងៗ មកថ្វាយ មកបូជា ជាបដិការតបគុណឥតគណនាត្រារាប់បានឡើយ។

សមដូចព្រះពុទ្ធភាសិតថា:

**សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ**

**យំយំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ។**

បុគ្គលអ្នកមានសទ្ធា១ មានសីល១ មានយសស័ក្តិ១ មានភោគសម្បត្តិច្រើន១ (ទាំង៤ពួកនេះ) ចង់ចង់ស្ថានមេត្រីនឹងប្រទេសធំៗណាៗ មនុស្សក្នុងប្រទេសធំៗនោះៗ ចោមរោមគោរពរាប់អាន បូជាដោយលាភសក្ការៈ (ច្រើនឥតបើគណនាបានឡើយ)។ យើងទាំងឡាយឃើញច្បាស់នឹងភ្នែករាល់គ្នាហើយ ដូចផ្លូវថ្នល់ទៅកាន់ដែកំពង់សោម ដែលហៅថាទីក្រុងព្រះសីហនុ ជាដើមនេះ។ ម្យ៉ាងទៀត សូម្បីព្រះអង្គជាវិសុទ្ធិពង្សជាអគ្គបុរសរដ្ឋ ជាព្រះបិតាឯករាជ្យជាតិម្ល៉េះហើយ ក៏គង់ទ្រង់ប្រើព្រះឥរិយាបថស្មើជាដរាប ដូចជាទ្រង់ចេញសាងព្រះផ្នួសក្លាមទ្រង់ចេះទេសនាទូន្មានមហាសប្បុរសបាន ស្តាប់ពីរោះអស្ចារ្យ ដូចជាអង្គព្រះបរមពោធិសត្វដែលកំពុងសាងបំពេញបារមី ជិតនឹងបានត្រាស់ដូច្នោះដែរ ទ្រង់បំពេញទសពិធរាជធម៌១០យ៉ាងគឺៈ[១] ១-ទានៈ ទ្រង់ព្រះរាជទានសាលារៀនទាំង៦។ ២-សីលំ

១–មើលក្នុងគម្ពីរលោកន័យពិស្តារចុះ។

ទ្រង់បញ្ចសីលជាប់ជានិច្ច។ ៣-បរិច្ចាគំ ទ្រង់លះសម្បត្តិនិងលះកម្លាំងព្រះកាយពលជាដើមបម្រើជាតិឥតធុញទ្រាន់ឬស្តាយស្រណោះឡើយ។ ៤-អាជ្ជវំ ទ្រង់មានព្រះហឫទ័យស្មោះត្រង់ស្មើនឹងរាស្ត្រ។ ៥-មទ្ទវំ ទ្រង់មានព្រះហឫទ័យត្រជាក់ជាទីជ្រកពឹងពាក់សត្វ។ ៦-តបំ ទ្រង់ឧបោសថសីលឬព្យាយាមដុតកិលេសឲ្យក្តៅសព្វជាធម្មតា។ ៧-អក្កោធំ ទ្រង់មិនក្រោធវិរោធ តែងមានព្រះមេត្តា។ ៨-អវិហឹសា ទ្រង់ផ្សាយករុណាដោះទុក្ខសត្វដោយឥតទារយកកម្រៃ។ ៩-ខន្តិ ទ្រង់អំណត់ធន់ទ្រាំនឹងពាក្យពោលមួលបង្កាច់។ ១០-អវិរោធនំ ទ្រង់ព្រះមេត្តាប្រោសដោះលែងមនុស្សជាប់ទោស។

**ឯតេ ទសវិធា ធម្មា រាជូនំ រាជធម្មិកា**

ធម៌ទាំង១០ប្រការនេះ ព្រះរាជាអង្គណាបានទ្រទ្រង់គ្រប់ទាំង១០ ព្រះរាជាអង្គនោះទ្រង់ព្រះនាមថា ព្រះបាទធម្មិកៈដោយពិត។ គឺស្តេចទសពិធដែលហៅថា ស្តេចទ្រង់ធម៌១០ប្រការនោះឯង។ សម្តេចព្រះបិតាឯករាជ្យជាតិ ស្តេចទ្រទ្រង់ធម៌១០ប្រការនេះមែនពិតហើយ ទើបព្រះកិត្តិគុណព្រះអង្គ ល្បីរន្ទឺរលាន់ឮសាយភាយក្រអូបឈ្ងុយឈ្ងប់ពេញទាំងពិភពលោកៗ គេទទួលស្គាល់ឯករាជ្យ អាព្យាក្រិតបរិបូណ៌ដោយសន្តិភាពនៃ

ប្រទេសកម្ពុជារបស់ព្រះអង្គ ប្រទេសមហាអំណាចទាំងប៉ុន្មានក៏ នាំគ្នាចុះចូលស្រឡាញ់គោរពរាប់អាន លើកតម្កើងឲ្យថ្កើងស្មើនឹងគេដែរ បើទុកជាព្រះអង្គមានអំណាចប៉ុន្មានក្តី ក៏ទ្រង់នៅក្នុងធម៌រាបសាជាធម្មតា ទ្រង់មិនចេះវាយឫកឬឆ្មើងឆ្មៃឬប្រកាន់មានះ ប្រមាថពាធាទៅលើចាស់ក្មេងឬឥស្សរជនណាមួយឡើយ បើជនណាប្រព្រឹត្តល្មើសខុសច្បាប់ត្រូវទោសទណ្ឌកម្មក៏ទ្រង់មិនប្រកាន់ថាស្រេចនឹងព្រះអង្គឡើយ គឺទ្រង់លើកលែងឬទ្រង់ផ្ទេរឲ្យទៅមហាសន្និបាតជំនុំជម្រះ សម្រេចដោយអនុគ្រោះជាដរាប។ ត្រង់នេះហើយទើបព្រះកិត្តិគុណរបស់សម្តេចក្លាយទៅជាព្រះបាទធម្មិករាជ ជាស្តេចប្រកបដោយធមិ, ឈ្មោះថាព្រះអង្គបានបំពេញសង្គហវត្ថុទាំង៤ ដែលហៅថា **សមានត្តតា** ទាំងធម្មាធិដ្ឋាននិងបុគ្គលាធិដ្ឋានពេញទំហឹង។ បើអស់លោកទាំងឡាយព្យាយាមប្រព្រឹត្ត តាមមាគ៌ានយោបាយ សង្គហវត្ថុទាំង៤ប្រការនេះឲ្យដូចជាសម្តេចដែលទ្រង់បានត្រួសត្រាយទុកឲ្យ នោះយើងរាល់គ្នាមុខជានឹងជួបប្រទះសេចក្តីសុខ សេចក្តីចម្រើនក្នុងពុទ្ធចក្រនិងអាណាចក្រ ទាំងបានជួបប្រសព្វនឹងគុណព្រះរតនត្រ័យជាឧត្តមសរណៈរាល់ៗវេលាដរាបដល់ព្រះនិព្វានពុំឃ្លាតឡើយ។

១–អធិប្បាយអំពីសង្គហវត្ថុ៤ប្រការ

២–សម្បទា៧ប្រការ

៣–ប្រយោជន៍៣ប្រការ

៤–ព្រមទាំងឧទាហរណ៍ប្រៀបធៀបនឹងព្រះប្រិយមហាក្សត្រ។

**សូមបញ្ចប់ដោយសង្ខេបប៉ុណ្ណេះឯង**

ស្រាវជ្រាវដោយៈ ជាច់ សុតឹម